# មូលនិធិក្រុង ស្រុក

១.គោលដៅ និងវិសាលភាព

២.ប្រភពធនធាន និងការគ្រប់គ្រងមូលនិធិក្រុង ស្រុក

៣.ការវិភាជន៍ និង ការផ្ទេរធនធានមូលនិធិក្រុង ស្រុក

៤.ការប្រើប្រាស់ធនធានមូលនិធិក្រុង ស្រុក

## ១.គោលដៅ និងវិសាលភាព

- គោលដៅ ៖ កំណត់ក្របខ័ណ្ឌគតិយុត្ត សម្រាប់ផ្តល់ធនធានហិរញ្ញវត្ថុមួយចំណែកប្រកបដោយសមធម៌ ចីរភាព និងអាចព្យាករណ៍បានដល់រដ្ឋបាលក្រុង ស្រុក ដើម្បីជួយទ្រទ្រង់ និងអភិវឌ្ឍមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- វិសាលភាព ៖ គ្របដណ្តប់លើការគ្រប់គ្រងមូលនិធិក្រុង ស្រុក ក្នុងការផ្តល់មូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌពីថវិកាជាតិ និងពីប្រភពផ្សេងៗ។

## ២.ប្រភពធនធាន និងការគ្រប់គ្រងមូលនិធិក្រុង ស្រុក

**ប្រភពធនធាននៃមូលនិធិក្រុង ស្រុករួមមាន ៖**

- ការចូលរួមពីចំណូលចរន្តនៃថវិការដ្ឋ
- ការរួមចំណែកពីដៃគូអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ
- ការចូលរួមដែលកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗ

**កម្រិតនៃការផ្ទេរពីថវិកាជាតិទៅក្នុងគណនីមូលនិធិក្រុងស្រុក សម្រាប់ឆ្នាំ២០១២ ដល់២០១៤ ៖**

- ថវិកាឆ្នាំ២០១២មានចំនួន0,៨0% នៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១១
- ថវិកាឆ្នាំ២០១៣មានចំនួន0,៨0% នៃចំណូលចរន្តថវិកាជាតិដែលនឹងត្រូវអនុម័តឆ្នាំ២០១២
- ថវិកាឆ្នាំ២០១៤មានចំនួន0,៨0% នៃចំណូលចរន្តថវិកាជាតិដែលនឹងត្រូវអនុម័តឆ្នាំ២០១៣

## តួនាទី ភារកិច្ចរបស់ស្ថាប័នពាក់ព័ន្ធ៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- គ.ជ.អ.ប

## ៣.ការវិភាជន៍ និងការផ្ទេរធនធានមូលនិធិ ក្រុង ស្រុក

## ធនធានមូលនិធិក្រុង ស្រុកត្រូវចែកចេញជា ២សមាសភាគគឺ៖

- សមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ
- សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន

**ទំហំធនធានសមាសភាគប្រតិបត្តិការទូទៅ ត្រូវបាន កំណត់ផ្អែកលើឯកតា រង្វាស់ និងនិយាមដូចខាងក្រោម ៖**

- ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក
- ប្រាក់បៀវត្សសម្រាប់គណៈអភិបាល និងបុគ្គលិករបស់ រដ្ឋបាលក្រុង ស្រុក
- គម្រោងចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗមិនឱ្យលើសពី ២៤%នៃធនធានមូលនិធិសរុប *ដក* ប្រាក់ឧបត្ថម្ភរបស់ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក និងប្រាក់បៀវត្សរបស់ គណៈអភិបាល និងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក

# ទំហំធនធានសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន

ស្មើនឹងធនធានវិភាជន៍សរុប

**ដក**

ទំហំធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ

**វិធាននៃការបែងចែកធនធានសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ ទៅរដ្ឋបាលក្រុង ស្រុកនីមួយៗ ៖**

- ចំណាយប្រាក់ឧបត្ថម្ភ និងប្រាក់បៀវត្សរបស់សមាជិកក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិករដ្ឋបាលក្រុង ស្រុក
- សន្ទស្សន៍សម្រាប់បែងចែកធនធានសម្រាប់ចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗ៖

➢ ចំណែកស្មើគ្នា ចំនួន ៤០%

➢ ចំនួនសមាជិកក្រុមប្រឹក្សា ចំនួន ២០%

➢ ចំនួនគណៈអភិបាល ចំនួន ២០%

➢ ចំនួនមន្ត្រី បុគ្គលិកសរុប ចំនួន ២០%

## ធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋានត្រូវបាន វិភាជន៍ គណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម៖

- ចំណែកស្មើគ្នាជាមូលដ្ឋានចំនួន ៤០%
- ចំនួនប្រជាពលរដ្ឋចំនួន ២០%
- សន្ទស្សន៍ភាពក្រីក្រចំនួន ២០%
- ចំនួនឃុំ សង្កាត់ចំនួន ២០%

## កាលវិភាគនៃការបោះផ្សាយអាណត្តិរបស់ សហវ ក្នុង ការផ្ទេរពីគណនីថវិការដ្ឋទៅគណនីដោយឡែករបស់ មូលនិធិក្រុង ស្រុកនៅរតនាគារជាតិ ៖

- ៥០%នៃមូលនិធិសរុបយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែឧសភា
- ៨០%នៃមូលនិធិសរុបយ៉ាងយូរត្រឹម ថ្ងៃទី៣១ ខែសីហា
- ១០០%នៃមូលនិធិសរុបយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែតុលា

## ការផ្ទេរធនធានមូលនិធិក្រុង ស្រុកជូនទៅក្រុង ស្រុក នីមួយៗត្រូវធ្វើឡើងជាបួនដំណាក់កាល ៖

- នៅដើមត្រីមាសទី១ សហវ ត្រូវបញ្ជាផ្ទេរចំណាយចំនួន ១/៤ នៃមូលនិធិប្រចាំឆ្នាំ
- ត្រីមាសទី២ ទី៣ និងទី៤ រដ្ឋបាលក្រុង ស្រុកត្រូវធ្វើសំណើសុំផ្ទេរមូលនិធិទៅ សហវ តាមរយៈ ក្រសួងមហាផ្ទៃនៅដើមខែទីបីនៃត្រីមាសមុន ដោយភ្ជាប់នូវរបាយការណ៍ចំណូល ចំណាយថវិកាដែលបានអនុវត្តនៅត្រីមាសមុនៗ និងរបាយការណ៍ប៉ាន់ស្មានអនុវត្តចំណូល ចំណាយថវិកាសម្រាប់ត្រីមាសបន្ទាប់

## ៤.ការប្រើប្រាស់ធនធានមូលនិធិក្រុង ស្រុក

## ក.សមាសភាគរដ្ឋបាលទូទៅ ៖

- ចំណាយចរន្តទាំងឡាយដែលពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការរដ្ឋបាលក្រុង ស្រុក
- ចំណាយមូលធនទាំងឡាយណាដែលពាក់ព័ន្ធនឹងកិច្ចអភិវឌ្ឍន៍ ឬលទ្ធកម្មលើអចលនទ្រព្យសម្រាប់ប្រើប្រាស់ក្នុងបុព្វហេតុរដ្ឋបាល

## ខ.សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន៖

- ចំណាយចរន្តទាំងឡាយណាដែលពាក់ព័ន្ធនឹងការផ្តល់សេវាមូលដ្ឋាន កិច្ចប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងបរិក្ខារផ្សេងៗទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ការផ្តល់សេវាទាំងនោះ
- ចំណាយមូលធនដែលពាក់ព័ន្ធទៅនឹងការវិនិយោគក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ។

# សូមអរគុណ!